**សលាកប័ត្រព័ត៌មាន ៖** សកម្មជនអង្គការមាតាធម្មជាតិត្រូវបានកំណត់មុខសញ្ញាជាថ្មី
**កាលប្បវត្តិ ៖ ខែធ្នូ ឆ្នាំ២០១៥**
**ទិដ្ឋភាពរួម ៖** ការឃុំខ្លួនដោយខុសច្បាប់នាពេលថ្មីៗលើសកម្មជនអង្គការមាតាធម្មជាតិ និងប្រជាសហគមន៍ក្នុងខេត្តកោះកុងគឺជាព្រឹត្តិការណ៍ចុងក្រោយបង្អស់មួយក្នុងចំណោមព្រឹត្តិការណ៍នានាមានគោលបំណងរារាំងក្រុមសកម្មជនអង្គការមាតាធម្មជាតិមិនឱ្យអនុវត្តសិទ្ធិមូលដ្ឋានរបស់ពួកគេ។

## សេចក្តីផ្តើម

ផ្ទុយទៅនឹងសាវតារនៃការបង្ក្រាបកាន់តែខ្លាំងទៅលើអង្គការការពារបរិស្ថានឈ្មោះមាតាធម្មជាតិសលាកប័ត្រព័ត៌មាននេះនឹងវិភាគអំពីការឃុំខ្លួននាពេលថ្មីៗទៅលើសកម្មជន និងប្រជាសហគមន៍ជាច្រើននាក់ដែលមានទំនាក់ទំនងជាមួយអង្គការមាតាធម្មជាតិ។ នៅក្នុងព្រឹត្តិការណ៍នោះ ជនរងគ្រោះត្រូវបានឃុំខ្លួននិងសាកសួរអស់រយៈពេលជាច្រើនម៉ោងដែលនេះជាការរំលោភលើច្បាប់កម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ នេះជាព្រឹត្តិការណ៍ចុងក្រោយបង្អស់ក្នុងចំណោមព្រឹត្តិការណ៍នានា ដែលបង្ហាញពីករណីរំលោភទៅលើសេរីភាពមូលដ្ឋាននៅក្នុងខេត្តកោះកុងដែលកើតឡើងពាក់ព័ន្ធនឹងក្រុមហ៊ុនឯកជននិងអាជ្ញាធរខេត្តកោះកុង។

សលាកប័ត្រព័ត៌មាននេះតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា("ម.ស.ម.ក") ដែលជាអង្គមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យ ឈានមុខដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅកម្ពុជា។

## សាវតារ ៖ ការបូមខ្សាច់ និងអង្គការមាតាធម្មជាតិ

ចាប់តាំងពីបានបង្កើតឡើងក្នុងឆ្នាំ២០១២ អង្គការមាតាធម្មជាតិបានក្លាយជាចលនាមូលដ្ឋាននាំមុខនៃសកម្មជនបរិស្ថានដែលតស៊ូស្វិតស្វាញប្រឆាំងទៅនឹងការបំផ្លិចបំផ្លាញដ៏រាលដាលលើធនធានធម្មជាតិដោយសារសកម្មភាពរបស់ក្រុមហ៊ុនឯកជននៅក្នុងខេត្តកោះកុង។ យុទ្ធនាការរបស់អង្គការមាតាធម្មជាតិនាពេលបច្ចុប្បន្ននេះគឺប្រឆាំងទៅនឹងសកម្មភាពបូមខ្សាច់នៅក្នុងព្រែកនៃខេត្តកោះកុងដែលបានចាប់ផ្តើមឡើងក្នុងខែមេសាឆ្នាំ២០១៥ហើយត្រូវបានប្រឆាំងជាខ្លាំងពីសំណាក់ក្រុមហ៊ុនឯកជននិងអាជ្ញាធរខេត្តកោះកុងដែលនាំឱ្យមានការចាប់ខ្លួនជាច្រើនដង។

ការបូមខ្សាច់នៅក្នុងខេត្តកោះកុងបានកើតឡើងតាំងពីឆ្នាំ២០០៨ ហើយបន្តកើតឡើងឥតស្រាកស្រាន្តដោយសារកង្វះខាតការវាយតម្លៃលើផលប៉ះពាល់ និងការរាយការណ៍ឲ្យបានត្រឹមត្រូវ។ ការអនុវត្តនេះពាក់ព័ន្ធនឹងសកម្មភាពបូមនិងដឹកជញ្ជូនខ្សាច់ពីបាតព្រែកដែលជាសកម្មភាពមិនមាននិរន្តរភាពជាប់លាប់ ហើយជាញឹកញាប់សកម្មភាពនេះនាំឱ្យមានការហូរច្រោះដីនិងធ្លាប់បាក់ច្រាំងព្រែក។ ទូកដែលដឹកជញ្ជូនខ្សាច់ពីម៉ាស៊ីនបូមស្ងួចខ្សាច់នោះបានធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅដល់ជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន ដោយបានបំផ្លិចបំផ្លាញនូវទ្រព្យសម្បត្តិដូចជាទ្រូចាប់ក្តាមនិងឧបករណ៍នេសាទផ្សេងៗទៀត។ យោងតាមលិខិតមួយច្បាប់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឆ្លើយតបទៅនឹងការចោទសួរពីតំណាងរាស្ត្រគណៈបក្សជំទាស់លោក

ស៊ុន ផ័យ ដែល (ម.ស.ម.ក) ទទួលបាន បានសរសេរថាការបូមខ្សាច់ទាំងអស់នៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជាគឺធ្វើឡើងក្នុងគោលបំណងសម្រាប់នាំចេញតែប៉ុណ្ណោះ។

ទិដ្ឋភាពដ៏គួរឱ្យព្រួយបារម្ភបំផុតមួយនៃបញ្ហាបូមខ្សាច់ គឺកង្វះតម្លាភាពឬកង្វះខាតជុំវិញការផ្តល់សិទ្ធិអំណាច និងភាពស្របច្បាប់នៃសកម្មភាពបូមខ្សាច់ទាំងនោះ។ មកទល់ពេលនេះរដ្ឋាភិបាលបានខកខានក្នុងការចេញអាជ្ញាប័ណ្ណដែលបានផ្តល់ទៅឱ្យក្រុមហ៊ុនបូមខ្សាច់ទាំងនោះ ក្នុងនោះរួមមានទាំងក្រុមហ៊ុនឧត្តមសីម៉ាផងដែរ ឬក៏បរាជ័យក្នុងការវាយតម្លៃអំពីផលប៉ះពាល់សង្គមនិងបរិស្ថានឱ្យបានត្រឹមត្រូវទៅតាមច្បាប់នៅមុនពេលផ្តល់អាជ្ញាប័ណ្ណ។ ដូច្នេះមិនមានមធ្យោបាយណាមួយដើម្បីត្រួតពិនិត្យពីនីត្យានុកូលភាពនៃសកម្មភាពរបស់ក្រុមហ៊ុនបូមខ្សាច់ក្នុងខេត្តកោះកុងក៏ដូចជាកន្លែងផ្សេងទៀតនោះឡើយ។ សកម្មភាពនេះមាននិន្នាការបម្រើផលប្រយោជន៍ដល់សាជីវកម្មដែលជាប់ពាក់ព័ន្ធ ដោយធ្វើឱ្យពួកគេអាចបន្តសកម្មភាពបូមខ្សាច់ប្រកបដោយនិទណ្ឌភាពស្ទើរតែទាំងស្រុងនិងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសហគមន៍ដែលរស់នៅពឹងផ្អែកក្នុងតំបន់នោះ។

ឧត្តមសីម៉ា គឺជាក្រុមហ៊ុនដ៏មានឥទ្ធិពលមួយដែលត្រូវបានគេស្គាល់តិចតួច។ ប៉ុន្តែយោងតាមឯកសាររបស់ក្រសួងពាណិជ្ជកម្មដែល ម.ស.ម.ក ទទួលបាន បង្ហាញថាលោកជំទាវ ហ៊ុន ម៉ាណា និងលោកជំទាវ ហ៊ុន ម៉ាលី(ដែលបានរៀបការជាមួយកូនប្រុសរបស់លោកឧបនាយករដ្ឋមន្ត្រីសុខ អាន) ដែលជាកូនស្រីរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាម្ចាស់ភាគហ៊ុននៃក្រុមហ៊ុននេះរហូតដល់ពាក់កណ្តាលឆ្នាំ២០១១[1] នៅពេលនោះភាគហ៊ុនរបស់ពួកគេត្រូវបានប្រគល់ទៅឱ្យស្ត្រីកម្ពុជាម្នាក់ឈ្មោះសារិន ដាលីន។

## ព្រឹត្តិការណ៍ចុងក្រោយបំផុត ៖ ការឃុំខ្លួនដោយខុសច្បាប់ពីសំណាក់ក្រុមហ៊ុនបូមខ្សាច់ឧត្តមសីម៉ា

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៥ មនុស្សចំនួន ៧ នាក់ត្រូវបានឃុំខ្លួនអស់រយៈពេលប្រមាណជាពីរម៉ោងដោយសន្តិសុខឯកជនដែលជួលដោយក្រុមហ៊ុនឧត្តមសីម៉ា ជាក្រុមហ៊ុនបូមខ្សាច់មួយនៅក្នុងខេត្តកោះកុងដែលបានអះអាងថាសកម្មជនទាំងនោះបានថតសកម្មភាពបូមខ្សាច់របស់ពួកគេដោយខុសច្បាប់។ អ្នកដែលត្រូវបានសន្តិសុខក្រុមហ៊ុនចាប់ខ្លួនទាំងនោះមានឈ្មោះ រ៉ូដ ហាប៊ីនសុន (Rod Harbinson) ជាអ្នកសារព័ត៌មានជនជាតិអង់គ្លេស សកម្មជនអង្គការមាតាធម្មជាតិលោក ចេក នីត្រា លោក ម៉ូត គឹមរី ព្រមទាំងប្រជាសហគមន៍មូលដ្ឋានដូចជាលោក ខៀវ សាឡេះ ម៉ូត សុផា ឡឹម សុជាតា និងក្មេងស្រីម្នាក់ទៀត។

យោងតាមលោក ម៉ូត គឹមរី សកម្មជនទាំងនោះស្ថិតនៅលើដីសាធារណៈថតយករូបភាពសកម្មភាពបូមខ្សាច់ដែលបានកើតមានឡើងក្នុងតំបន់ព្រៃកោងកាងនៅក្បែតំបន់កោះស្មាច់ ដែលពួកគេបានសង្ស័យថាជាសកម្ម ភាពខុសច្បាប់។ ពួកគេត្រូវបានតំណាងក្រុមហ៊ុនឧត្តមសីម៉ាប្រាប់ថាសកម្មភាពរបស់ក្រុមហ៊ុនគឺស្របច្បាប់និងថាមានលិខិតបញ្ជាក់ពីការអនុញ្ញាតឲ្យធ្វើអាជីវកម្មត្រឹមត្រូវ។ នៅពេលចាប់ខ្លួនសកម្មជនទាំងនោះត្រូវបានបញ្ជាឱ្យលុបរូបថតវីដេអូនោះចោលវិញ តំណាងក្រុមហ៊ុនបានប្រាប់ពួកគេថារាល់ការថតរូបភាពនៅទីនេះត្រូវតែមានការអនុញ្ញាតពីខ្លួននិងអាជ្ញាធរមូលដ្ឋាន។ ដើម្បីទប់ស្កាត់កុំឱ្យមានស្ថានភាពកាន់តែធ្ងន់ធ្ងរ ក្រុមសកម្មជនក៏បានយល់ព្រមឱ្យសន្តិសុខក្រុមហ៊ុនលប់រូបភាពទាំងនោះចេញវិញ។ ទោះជាយ៉ាងនោះក្តី សកម្មជន

---

[1] ឃួន ណារីម "អង្គការចោទប្រកាន់ក្រុមហ៊ុនបូមខ្សាច់ឃុំខ្លួនមនុស្សខុសច្បាប់" កាសែត *ដឹ ខេមបូឌា ដេលី* ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ អាចស្វែងរកបានតាមរយៈ ៖ https://www.cambodiadaily.com/news/ngo-accuses-sand-dredging-company-of-illegal-detention-105076/។

ទាំងនោះនៅតែត្រូវបានសន្តិសុខឃាត់មិនឱ្យចាកចេញ ហើយត្រូវបាននាំខ្លួនទៅកាន់ទីតាំងទីពីជាកន្លែងដែលពួកគាត់ត្រូវបានសាកសួរអស់រយៈពេលជាងមួយម៉ោង។ បន្ទាប់ពីរងការបំភិតបំភ័យប្រមាណជាងមួយម៉ោងកន្លះពីសំណាក់សន្តិសុខមក ទើបពួកគេត្រូវបានដោះលែងវិញ។

លោក អៀត ប៊ុនថុល អ្នកនាំពាក្យក្រុមហ៊ុនឧត្តមសីម៉ា(ក្រុមហ៊ុនបូមខ្សាច់ពាក់ព័ន្ធក្នុងករណីនេះ) ថ្លែងថា ក្រុមហ៊ុនរបស់លោកទទួលបានអាជ្ញាប័ណ្ណពីរាជរដ្ឋាភិបាលក្នុងការធ្វើអាជីវកម្មបូមខ្សាច់និងនាំខ្សាច់ចេញ ហើយថា សកម្មជននិងប្រជាសហគមន៍ទាំងនេះចុះទៅកាន់ទីនោះដោយពុំមានការអនុញ្ញាតត្រឹមត្រូវពីក្រសួងរ៉ែនិងថាមពល ហេតុដូចនេះសកម្មភាពរារាំងរបស់ក្រុមសន្តិសុខគឺសមហេតុផល។ ផ្ទុយពីការលើកឡើងនេះ គ្មានការបញ្ជាក់ផ្លូវការណាមួយពីក្រសួងរ៉ែនិងថាមពលទេរហូតមកទល់ពេលនេះដែលបញ្ជាក់ថាក្រុមហ៊ុនបូមខ្សាច់ឧត្តមសីម៉ាមានអាជ្ញាប័ណ្ណស្របច្បាប់ហើយអង្គការមាតាធម្មជាតិក៏មិនមានលទ្ធភាពទទួលបានកំណត់ហេតុបញ្ជាក់ពីការអនុញ្ញាតទាំងនេះដែរ។ លោក នីត្រា ដែលមានវត្តមានក្នុងព្រឹត្តិការណ៍នោះបាននិយាយថាសន្តិសុខក្រុមហ៊ុនស្នើឱ្យក្រុមសកម្មជនលុបរូបភាព និងវីដេអូចោលព្រោះថៅកែពួកគេមិនបានអនុញ្ញាតឡើយ។ សកម្មជនទាំងនោះមិនរងការវាយដំ ឬ ប៉ះពាល់លើរូបរាងកាយពីសំណាក់សន្តិសុខក្រុមហ៊ុនទេប៉ុន្តែតម្រូវឱ្យបង្ហាញអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន តែសកម្មជនទាំងនោះមិនព្រមធ្វើតាម។ ក្នុងចំណោមអ្នកទាំងបួននាក់ដែលត្រូវបានឃាត់ខ្លួនរួមមានលោក ម៉ូត គឹមរី ចេក នីត្រា ម៉ូត សុផា និង ឡឹម សុជាតា បានដាក់ពាក្យបណ្តឹងទៅកាន់ព្រះរាជអាជ្ញារអមសាលាដំបូងខេត្តកោះកុងនៅថ្ងៃទី២៨ ខែធ្នូ ទាក់ទងនឹងហេតុការណ៍នេះ។

## ច្បាប់ ៖ សេរីភាពខាងការបញ្ចេញមតិ និងការហាមប្រាមក្នុងការឃាត់ខ្លួនដោយខុសច្បាប់

សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងការហាមប្រាមក្នុងការឃាត់ខ្លួនដោយខុសច្បាប់ត្រូវបានការពារក្រោមច្បាប់ជាតិកម្ពុជា។ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ចែងថា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ។ បទប្បញ្ញត្តិនេះរួមបញ្ចូលទាំងសេរីភាពក្នុងការថតរូបដូចក្នុងករណីនេះផងដែរ។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញបានហាមមិនឲ្យមានការ "ចោទប្រកាន់ ការចាប់ខ្លួន ឬការឃាត់ខ្លួនបុគ្គលណាម្នាក់ឡើយ លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។ ដូចគ្នានេះមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថា "*បុគ្គលដែលចាប់ ដែលឃុំឃាំង ឬដែលបង្ខាំងបុគ្គលផ្សេងទៀតដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់*" គឺជាការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីនេះសបញ្ជាក់ឲ្យឃើញថាការចាប់ខ្លួននោះគឺមិនអនុលោមតាមច្បាប់ឡើយ ហើយផ្ទុយនឹងរដ្ឋធម្មនុញ្ញនិងក្រមព្រហ្មទណ្ឌកម្ពុជា។

បន្ថែមលើនេះមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស("ស.ប.ស.ស") និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្សតាមរយៈការដាក់បញ្ចូល ស.ប.ស.ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") នៅក្នុងច្បាប់ជាតិ។ មាត្រា ៩ នៃ ស.ប.ស.ស និងមាត្រា ៩ នៃ ក.អ.ស.ព.ន ដែលរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល")បានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩២ ដែលបទប្បញ្ញត្តិទាំងពីរនេះហាមប្រាមក្នុងការឃាត់ខ្លួនតាមអំពើចិត្ត។

ម្យ៉ាងទៀតយោងតាមគោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ទាំងក្រុមហ៊ុនឧត្តមសីម៉ានិងរដ្ឋាភិបាលមានកាតព្វកិច្ចគោរពសិទ្ធិមនុស្សគ្រប់យ៉ាង។ គោលការណ៍ណែនាំនេះចែង

បន្ថែមទៀតថា រដ្ឋត្រូវតែផ្តល់សំណងគ្រប់គ្រាន់និងសមរម្យចំពោះការរំលោភបំពានសិទ្ធមុស្សដែលជាការទទួលខុសត្រូវរបស់ក្រុមហ៊ុន។ តាមការលើកឡើងខាងលើ ក្នុងករណីនេះក្រុមហ៊ុនឧត្តមសីម៉ាបានរំលោភទៅលើសិទ្ធិសកម្មជនទាំងនោះដែលត្រូវបានបង្ខាំងទុកដោយតំណាងក្រុមហ៊ុនដូច្នេះរដ្ឋាភិបាលមានកាតព្វកិច្ចផ្តល់សំណងដោយបើកឱ្យមានការស៊ើបអង្កេតជាបន្ទាន់និងប្រកបដោយប្រសិទ្ធភាពតាមផ្លូវតុលាការ ។

**សាខានារ ៖ ការបង្ក្រាបកាន់តែខ្លាំងទៅលើអង្គការមាតាធម្មជាតិ**

នៅថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ២០១៣ លោក អាឡិចហ្សង់ដ្រូ ហ្គន់សាឡេស ដែលជាសហស្ថាបនិកអង្គការមាតាធម្មជាតិត្រូវបានឃុំខ្លួន និងត្រូវនិរទេសខ្លួនចេញពីប្រទេសតាមសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃដោយមិនបន្តសុពលភាពទិដ្ឋាការរបស់លោក។ ការនិរទេសខ្លួនលោក អាឡិចហ្សង់ដ្រូ ត្រូវបានមជ្ឈដ្ឋានទូទៅបកស្រាយថា គឺជាការបង្ហាញនូវចេតនាប៉ុនប៉ងជាយូរមកហើយរបស់រដ្ឋាភិបាលក្នុងការគាបសង្កត់ទៅលើការតស៊ូមតិរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងទប់ស្កាត់នូវមតិជំទាស់ក្នុងគោលបំណងបង្កើតនូវបរិយាកាសមួយដែលខ្លួនធ្វើសកម្មភាពដោយសេរី ការពារខ្លួនរួចផុតពីមតិរិះគន់ឯករាជ្យ។

នៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៥ សកម្មជនចំនួន ៣រូប ត្រូវបានឃុំឃាត់ខ្លួន ខណៈពេលកំពុងព្យាយាមដាក់ញត្តិទៅកាន់រដ្ឋសភាដូចបានលើកឡើងក្នុងរបាយការណ៍របស់ ម.ស.ម.ក នាពេលកន្លងមក។ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ យុវជនជាសមាជិករបស់អង្គការមាតាធម្មជាតិចំនួន ៣ រូបត្រូវបានចាប់ខ្លួនដាក់ពន្ធនាគារបន្ទាប់ពីបានបដិសេធចូលខ្លួនឆ្លើយបំភ្លឺនៅស្នងការនគរបាលស្រុកពាក់ព័ន្ធទៅក្នុងការចូលរួមតវ៉ាដោយសន្តិវិធីនិងអហិង្សាប្រឆាំងនឹងការបូមខ្សាច់។ ក្នុងអំឡុងខែមករាឆ្នាំ ២០១៥ សកម្មជនទាំងនោះបន្តស្ថិតនៅក្នុងការឃុំខ្លួន។ ហេតុការណ៍នេះនាំឱ្យមានការចាប់ខ្លួនមនុស្សចំនួន ១៧ នាក់ផ្សេងទៀត ក្នុងនោះរួមទាំងបុគ្គលិកសិទ្ធិមនុស្សចំនួនបួននាក់ និងអ្នកសារព័ត៌មានម្នាក់ផងដែរ ដែលត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នកាលពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ខណៈពេលមានការតវ៉ាឱ្យមានការដោះលែងសកម្មជនទាំងបីនាក់នោះ។ ស្ថានភាពនោះកាន់តែធ្ងន់ធ្ងរឡើង ដោយនៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៥ លោក វ៉ែន វ៉ន អ្នកដឹកនាំសហគមន៍ជនជាតិដើមភាគតិចដ៏លេចធ្លោនៅតំបន់អារ៉ែងដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយអង្គការមាតាធម្មជាតិត្រូវបានចាប់ខ្លួនហើយត្រូវបញ្ជូនទៅកាន់ពន្ធនាគារខេត្តកោះកុង នេះបើតាមការលើកឡើងក្នុងរបាយការណ៍របស់ ម.ស.ម.ក ។ រហូតមកទល់ពេលនេះ លោកវ៉ែន វ៉ន កំពុងស្ថិតនៅក្នុងការឃុំខ្លួននៅឡើយ ។

ជាមួយគ្នានេះដែរ កាលពីខែតុលា ឆ្នាំ២០១៥ វគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សមួយដែលត្រូវបានរៀបចំរួមគ្នាដោយអង្គការមាតាធម្មជាតិនិងអង្គការសមធម៌កម្ពុជាត្រូវបានលោកមេឃុំ និងនគរបាលស្រុកបទុមសាគរខេត្តកោះកុងបិទមិនឲ្យបន្តសកម្មភាព។ ជាការឆ្លើយតប អ្នកនាំពាក្យក្រសួងមហាផ្ទៃលោកខៀវ សុភ័ក្របានថ្លែងថា *"អាជ្ញាបានធ្វើរឿងត្រឹមត្រូវ...អង្គការមាតាធម្មជាតិតែងតែបង្កបញ្ហានិងញុះញង់ប្រជាពលរដ្ឋ"*។

**សេចក្តីសន្និដ្ឋាននិងអនុសាសន៍**

ក្រុមហ៊ុនឧត្តមសីម៉ាដ៏មានឥទ្ធិពល និងមានទំនាក់ទំនងយ៉ាងល្អជាមួយជនមានអំណាចត្រូវទទួលខុសត្រូវចំពោះការចាប់ និងការឃាត់ខ្លួនដោយខុសច្បាប់ទៅលើមនុស្សចំនួន ៧ នាក់ ក្នុងនោះរួមទាំងកុមារម្នាក់ផងដែលជាការរំលោភទៅលើច្បាប់កម្ពុជានិងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ព្រឹត្តិការណ៍នេះគឺជាព្រឹត្តិការណ៍ចុងក្រោយបង្អស់នៃការចាប់ខ្លួន និងឃុំខ្លួនដែលបានកើតឡើងឆ្លើយតបនឹងសកម្មភាពសន្តិភាពរបស់អង្គការមាតាធម្មជាតិ។ ម.ស.ម.ក ថ្កោលទោសចំពោះសកម្មភាពរបស់ក្រុមហ៊ុនឧត្តមសីម៉ា និងក្រុមហ៊ុនណាមួយដែលធ្វើសកម្មភាពរបស់ខ្លួនស្រដៀងគ្នានេះ។ រដ្ឋាភិបាលមានតួនាទីធានាថាសិទ្ធិរបស់សកម្មជនបរិស្ថានត្រូវបានការ

ពារនិងមានកាតព្វកិច្ចធានានូវតម្លាភាពនិងគណនេយ្យភាពចំពោះទង្វើរបស់ក្រុមហ៊ុននានាដែលទទួលបានអាជ្ញាប័ណ្ណជាផ្លូវការ។ ម.ស.ម.ក សូមជូនអនុសាសន៍ដល់រដ្ឋាភិបាលដូចខាងក្រោម ៖

- ម.ស.ម.ក ស្នើឱ្យធ្វើការស៊ើបអង្កេតជាបន្ទាន់និងឯករាជ្យមួយទៅក្នុងព្រឹត្តិការណ៍នៃការឃុំខ្លួនដោយខុសច្បាប់នេះ
- ម.ស.ម.ក ស្នើឱ្យធ្វើការចេញផ្សាយជាបន្ទាន់នូវរាល់អាជ្ញាប័ណ្ណដែលបានចេញទៅឱ្យក្រុមហ៊ុននានាពាក់ព័ន្ធក្នុងសកម្មភាពបូមខ្សាច់នៅក្នុងខេត្តកោះកុង ព្រមទាំងឯកសារវាយតម្លៃទៅលើផលប៉ះពាល់ផ្នែកសង្គមនិងបរិស្ថាន និងចេញផ្សាយនូវរាល់ឯកសារតាមផ្លូវច្បាប់ផ្សេងៗទៀត
- ម.ស.ម.ក សូមស្នើឱ្យមានការត្រួតពិនិត្យឡើងវិញឲ្យបានស៊ីជម្រៅនិងធ្វើការកែប្រែនូវនីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណបូមខ្សាច់ ដើម្បីដំណើរការប្រកបដោយតម្លាភាព មានការពិគ្រោះយោបល់និងបើកចំហឱ្យមានការពិនិត្យពិចៃជាសាធារណៈ
- ម.ស.ម.ក ស្នើរដ្ឋាភិបាលមេត្តាផ្តល់នូវកិច្ចការពារនិងធានានូវសន្តិសុខដល់សកម្មជននិងអ្នកការពារសិទ្ធិមនុស្សដែលមានជំហរប្រឆាំងនឹងការបំផ្លិចបំផ្លាញបរិស្ថាននិងជីវភាពរបស់ពលរដ្ឋមូលដ្ឋាន។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកស្រី ឆាយ ឈុនលី មន្ត្រីសម្របសម្រួលគម្រោងការពារសេរីភាពមូលដ្ឋានរបស់ម.ស.ម.ក តាមរយៈទូរសព្ទ +៨៥៥ (០)១៧ ៥២ ៨០ ២១ ឬអ៊ីម៉ែល ៖ chhunly.chhay@cchrcambodia.org ឬលោកផាត ដឺប្រូន ទីប្រឹក្សាម.ស.ម.ក តាមរយៈទូរសព្ទ ៖ + ៨៥៥ (០) ៨៩ ៥៣ ៦២ ១៥ ឬ អ៊ីម៉ែល ៖ pat.debrun@cchrcambodia.org។**

cc BY NC SA